


រឿង៖ មិត្តភាពមួយ
ដោយ៖ អាចម៍ផ្កាយ
«វិប្បដិសារីមួយ ដែលមិនអាច
បំភ្លេចបាន»

*រឿងហេតុដែលបានកើតឡើងទៅហើយនេះ វាពុំមែនជាការស្រមើស្រមៃរបស់អ្នកនិពន្ធទេ តែវាជាស្រមោលអតីតកាលដ៏ពិតមួយដែលបានកើតឡើងចំពោះមិត្តសំលាញ់ពីរនាក់ដែលរស់នៅក្នុងខេត្តកំពង់ចាម ។ ពួកគេគឺជាមិត្តចិត្តមួយថ្លើមមួយដែលបានចងសម្ព័ន្ធភាពជាមួយគ្នាតាំងពីនៅកុមារភាពម្ល៉េះ។*

*នារសៀលមួយម៉ោងប្រហែលជាពីរកន្លះ* ***ណារ៉ា****បានស្រែកឆោឡោដោយក្តីសប្បាយរត់មកកាន់ផ្ទះឈើដ៏តូចមួយ ។ ក្រោយមកណារ៉ាបានផ្តួលកង់ចោលនៅក្បែរមាត់របង ហើយរត់សំដៅចូលទៅក្នុងផ្ទះបំណងទៅជួប****ខេមរិន្ទ****ដែលកំពុងអង្គុយអានសៀវភៅនៅលើរានក្រោមផ្ទះនោះ ។ ណារ៉ារត់បណ្តើរស្រែកបណ្តើរថា ជាប់ហើយ! ជាប់ហើយ!...។ លុះមកដល់ទល់នឹងមុខខេមរិន្ទទើបណារ៉ាបន្ត:*

*–នែ! ខេមរិន្ទ គ្នាប្រលងជាប់ហើយណា នៅពេលនេះគ្នាបានទៅរៀនបន្តនៅភ្នំពេញហើយ តើឯងសប្បាយចិត្តដូចគ្នាដែរទេសំលាញ់?*

*–ឆ្កួត! មិត្តភក្តិប្រលងជាប់ទាំងមូល មិនសប្បាយចិត្តម៉េចនឹងកើត ។ ឯងនេះគ្រាន់តែរៀនក៏ចាំបាច់ទៅមើលឈ្មោះដែរ ។ គេគ្រាន់តែប្រលងហើយ គេដឹងថាជាប់ វាក៏ធ្លាក់ចាត់ទៅហើយ មិនមែនត្រូវមកអត់បាយក្រហាយទឹកព្រោះតែរង់ចាំមើលឈ្មោះយ៉ាងនេះទេ ហ្នឹងហើយមកពីមិនខំរៀន។*

*–ខ្ជិលនិយាយជាមួយឯងណាស់ អោយតែនិយាយរឿងរៀនម្តងណាគ្នាត្រូវមាត់រហូតអ៊ីចឹង គ្នាគិតរកទៅផ្ទះសិនហើយព្រោះពុកម៉ែកំពុងរង់ចាំដំណឹងផង។*

*–អើទៅចុះ! លំបាកដល់ឪពុកម្តាយឯងទៀត ចំមែន!*

ណារ៉ាត្រលប់មកផ្ទះដោយនាំសេចក្ដីសប្បាយមកជាមួយ... ប៉ុន្តែសេចក្ដីសប្បាយសំរាប់ថ្ងៃនេះមិនមែនបាន ន័យថានឹងបានសប្បាយតទៅហូតនោះទេ ព្រោះបន្តិចទៀតណារ៉ាត្រូវចាកចេញពីស្រុកកំណើត ជាមួយនឹងខេមរិន្ទ ដើម្បីបន្តការសិក្សានៅភ្នំពេញជាបន្តទៀត ។ ដំណើររឿងតទៅយ៉ាងណាគ្មាននរណាម្នាក់ដឹងទេ... មានតែទុកអោយព្រហ្មលិខិតជាអ្នកកំណត់ជោគជតារបស់ពួកគេទៅចុះ ។ ...មួយខែក្រោយមក ណារ៉ា និងខេមរិន្ទ បានមកដល់ផ្ទះចាស់មួយនៅឯជាយក្រុងដែលផ្ទះនោះស្ថិតក្នុងដីមួយកន្លែងតូចល្មម ។ ខណៈដែលមកដល់ ណារ៉ាក៏និយាយ :

–មកដល់ផ្ទះថ្មីហើយ ខេមរិន្ទឯងឃើញទេ ? នេះជាកន្លែងដែលយើងត្រូវតស៊ូជាមួយ គ្នាដើម្បីស្វែងរកអនាគតរបស់ពួកយើង ។ តែគ្នាគិតចង់ដើរមើលស្រុកទេសគេបន្តិចសិន ឯងទៅទេ ?

–មកដល់ភ្លាមចង់ដើរលេងភ្លាមឯងនេះ! គ្នាមិនទៅទេ គ្នានៅមើលសៀវភៅវិញព្រោះត្រូវត្រៀមខ្លួនចូលរៀនមហាវិទ្យាល័យផង បើរៀនមិនចេះគ្នាខ្មាសគេស្លាប់ហើយ ។

–ស្រេចចិត្តឯងចុះ! គ្នាមិនរំខានទេព្រោះឯងនេះដូចជាខ្មោចសៀវភៅទៅហើយ មួយថ្ងៃៗបើមិនបានអានសៀវភៅទេ ឯងវាឯាប់ ។

ខេមរិន្ទគ្រវីក្បាលហើយពោលតិចៗថា *ផ្ដាសមែន!* ។ តាមពិតទៅពួកគេចូលចិត្តលេងសើចជាមួយគ្នាណាស់ អាចនិយាយបានថាស្ទើរគ្រប់ពេលទៀតផង ។ អ្វីដែលខុសប្លែកគ្នាស្រលះរវាងពួកគេទាំងពីរនោះគឺខេមរិន្ទចូលចិត្តអានសៀវភៅ និងជាមនុស្សស្ងប់ស្ងាត់ពោរពេញដោយមនោសញ្ចេតនា ទាំងនោះខុសពីណារ៉ាស្រឡះព្រោះណារ៉ាចូលចិត្តលេងសើចច្រើន និងមិនចូលចិត្តអានសៀវភៅទេព្រោះគេយល់ថា ក្ដីសប្បាយជាវត្ថុសំខាន់ទីមួយនៃជីវិតរបស់គេ ។...លុះពេលណារ៉ាត្រលប់មកវិញ ខេមរិន្ទក៏សួរ :

–មកវិញហើយរឺ? បានអីផ្ញើគ្នាខ្លះ? ហើយសប្បាយទេ?

–គ្មានទេ! ព្រោះមិនមែនជាកាតព្វកិច្ច ។ រឿងអីដែលគ្នាត្រូវចំនាយពេលយូរតវ៉ាន់មកផ្ញើឯងនោះ?

–ត្រូវហើយ! ឯងធ្វើម៉េចនឹងមានចិត្តល្អបែបនោះទៅ ។...ហើយឯងយួរស្អីមកហ្នឹង?

ណារ៉ាទាញថង់ដាក់ត្របែកលាក់ក្រោយខ្នងហើយពោលថាគ្មានទេ តែតាមការពិតណារ៉ាមានបំនងយកមកផ្ញើខេមរិន្ទព្រោះដឹងថាខេមរិន្ទចូលចិត្តខ្លាំងណាស់ ។ បើនិយាយទៅទោះបីណារ៉ាលេងសើចច្រើន និងមិនសូវជាម្ចាស់ការក៏ពិតមែន ប៉ុន្តែគេមិនដែលភ្លេចតួនាទីជាមិត្តដ៏ល្អនោះទេ ។

-ត្របែក! គ្នាឃើញថាត្របែកណា យកមកក្លាយហេតុអីក៏ចាំបាច់លាក់?

-គ្នាចង់ដឹងថា មនុស្សអាក្រក់ដូចឯងនឹងស្តីអោយគ្នាបែបម៉េចបើគ្នាមិនបានទិញអីផ្ញើនោះ។

-តាមពិតគ្នាដឹងហើយថា ឯងមិនមែនជាមិត្តចិត្តយ៉ាងនោះទេ គ្នាធ្វើលេងទេតើសំលាញ់! យកកាំបិតមកចិតញ៉ាំទាំងអស់គ្នា គ្នាកំពុងតែឃ្លានស្រាប់ផង។ ពួកគេអង្គុយញ៉ាំបណ្តើរជជែកគ្នាបណ្តើរ ក្រោយមកខេមរិន្ទក៏សួរទៅណារ៉ា :

-ឯងមានចាំកាលពួកយើងអង្គុយញ៉ាំត្របែកនៅក្រោមដើមត្នោតមួយដែលដុះនៅក្បែរភ្លឺស្រែនោះទេ?... តើពួកយើងបានសន្យាអ្វីខ្លះជាមួយគ្នា?

-អឺ! ពួកយើងបានសន្យាថា ពួកយើងនឹងសាងក្តីស្រមៃមួយនោះអោយបានសម្រេចដែល ថាពួកយើងត្រូវតែមាន ជីវភាពធូរធារ ពួកយើងត្រូវមានផ្ទះធំ មានរថយន្ត មានគ្រប់សព្វដែលអ្នកដទៃកំពុងមាន តែពួកយើងនៅមិនទាន់មាន ពិសេសឯងមានបំណងមួយចង់ក្លាយជាអ្នកនិពន្ធដ៏ល្បីល្បាញ ។ សំលាញ់! គ្នាពិតជាចង់បានថ្ងៃនោះខ្លាំងណាស់។

-អ៊ីចឹងម៉េចក៏ឯងមិនខំរៀន?

-មិនដឹងយ៉ាងម៉េច ឃើញសៀវភៅចេះតែខ្ជិល! ប៉ុន្តែមិនអីទេ គ្នានឹងខំ។

- ហ្អឹង! ហ្អឹង! ហ្អឹង! គ្នាស្តាប់ឡើងទ្រលាន់ទៅហើយ ប៉ុន្តែមិនដែលឃើញអនុវត្តទាល់តែសោះ ។ ឯងត្រូវសន្យានឹងគ្នាមួយទៀតថា បើថ្ងៃក្រោយគ្មានគ្នានៅក្បែរក៏ឯងត្រូវតែតស៊ូសាងក្តីស្រមៃមួយ នេះអោយទាល់តែបានណាសម្លាញ់។

-អឺ! គ្នាដឹងហើយ។

ខេមរិន្ទទំលាក់ទឹកមុខចុះ ព្រោះក្នុងខ្លួនរបស់គេកំពុងតែអស់សង្ឃឹម ។ គេដឹងថាគេមិនអាច បាននៅ មើលថែមិត្តជាទីស្រលាញ់របស់គេបានជារៀងរហូតទេ ប៉ុន្តែគេពិតជាត្រូវការអោយមិត្តរបស់គេ មានសេចក្តីសុខលើគ្រប់អ្វីដែលពួកគេបានគិតទុកជាមួយគ្នា ។ ខេមរិន្ទ មានជំងឺដែលមិនអាចព្យាបាលបាន ព្រោះសុខភាពរបស់គេមិនអំណោយផលតាំងពីនៅកុមារភាពមកម្ល៉េះ ។ ខេមរិន្ទលួចសំលឹងមើលណារ៉ាដែលគិតតែពីលេងសើចដូចកូនក្មេងដែលមិនបានដឹងរឿងអ្វីសោះ ហើយខេមរិន្ទ គិតជាបណ្តើរៗនៅក្នុងចិត្តថា គ្នាចង់អោយឯងជាមនុស្សដែលមាន តែស្នាមញញឹមនិងក្តីសប្បាយជារហូតតទៅ ព្រោះទាំងអស់នោះជាវត្ថុសំខាន់ទីមួយនៃជីវិតរបស់ឯង។

គ្រប់អនុស្សាវរីយ៍នៃពួកគេទាំងពីរ គឺតែងតែត្រូវស្តែងចេញនូវភាពស្មោះត្រង់នឹងការលះបង់ ដើម្បីបំពេញតំលៃអោយមិត្តភាពដ៏វិសេសវិសាលរបស់ពួកគេ ។ នាព្រឹកមួយ ខេមរិន្ទក្រោកពីគេងទាំងមមីងមមាំងព្រោះឮសូរសំលេងណារ៉ាដាស់ :

–ខេមរិន្ទ! ខេមរិន្ទ! ក្រោកឡើងមកញ៉ាំថ្នាំ គ្នាទើបតែទិញមកផ្ញើឯង ។ មិនដឹងជា ហេតុអីទេ ? ... យប់មិញនេះឯងក្អករកតែគ្នាដេកពួនមិនបានទាល់តែសោះ ។

–សូមទោស!

–ឯងច្រលំទេដឹង?... មនុស្សឯងនេះចេះសូមទោសដែរ! ប្លែកមែន ។ អឺ! គ្នាត្រូវទៅរៀនគួរហើយ យប់នេះជួយបង្រៀនគ្នាបន្ថែមផង ។

–មិនអីទេអោយតែឯងចង់រៀន ណាស់តែហៅមកអោយរៀនហើយមិនចង់រៀនទេតើ!

និយាយគ្នាចប់ណារ៉ាក៏ដើរចេញទៅ ឯខេមរិន្ទយកថ្នាំដាក់ក្នុងមាត់បណ្តើរសម្លឹងមើល ណារ៉ាដែលកំពុងតែដើរទៅបណ្តើរ ។ ព្រឹកនេះ ខេមរិន្ទបានសំរេចចិត្តទៅមន្ទីរពេទ្យដើម្បីពិនិត្យថាតើទាំងអស់ នេះជាជម្ងឺអ្វី ? ខណៈនោះលោកគ្រូពេទ្យ មានប្រសាសន៍បញ្ជាក់ :

–វាជាជម្ងឺគ្រាំក្នុងដែលពាក់ព័ន្ធជាមួយសួត ជម្ងឺនេះអាចព្យាបាលបានតែក្នុងករណីដែលប្អូនមិនទាន់ធ្ងន់ធ្ងរតែប៉ុណ្ណោះ ។ តែនេះប្អូនទុកវារហូតដល់ក្អកមានឈាមទៅហើយ ដូច្នេះបញ្ហានេះសំរាប់គ្រូពេទ្យនៅប្រទេសរបស់យើងមិនអាចមានលទ្ធភាពគ្រប់គ្រាន់ទេ ។ មធ្យោបាយដែលល្អ គឺប្អូនត្រូវចេះ មើលថែសុខភាពរបស់ខ្លួនអោយបានល្អតែប៉ុណ្ណោះ ទើបធ្វើអោយប្អូនមានឱកាសរស់នៅបានយូរតទៅទៀត ។

–បាទ! អរគុណលោកគ្រូពេទ្យខ្លាំងណាស់ ខ្ញុំប្រាកដជាអនុវត្តតាមប្រសាសន៍របស់លោកគ្រូ ។ អីចឹងខ្ញុំគិតជំរាបលាលោកគ្រូសិនហើយ ។

–បាទ! សូមអញ្ជើញ ។

ខេមរិន្ទដើរចេញពីមន្ទីរពេទ្យដោយក្តីអស់សង្ឃឹម ។ មួយជំហានៗ ខេមរិន្ទគ្មានបារម្ភអ្វីក្រៅតែអំពីណារ៉ាទេព្រោះខេមរិន្ទជាកូនកំព្រាដែលរស់នៅជាមួយម្តាយមីង ហើយខេមរិន្ទមានតែណារ៉ាម្នាក់គត់ដែល ជាមិត្តដ៏សែនល្អរបស់គេ ។...អោយតែរាត្រីចូលមកដល់ ខេមរិន្ទតែងបង្រៀនណារ៉ារាល់យប់ ដោយមិនខ្វល់អំពីសុខភាពរបស់ខ្លួនឯងឡើយ ។ ពីរខែក្រោយមក ណារ៉ាបានក្លាយទៅជានិស្សិតដ៏ពូកែនៅក្នុងថ្នាក់ ប៉ុន្តែទន្ទឹមនឹងនោះ

សុខភាព របស់ខេមរិន្ទក៏ចុះខ្សោយណាស់ទៅហើយដែរ ទើបនៅក្នុងយប់មួយពេលដែលកំពុងបង្រៀនណារ៉ា ខេមរិន្ទស្រាប់តែក្អកជាខ្លាំងរហូតធ្វើអោយណារ៉ាបានដឹង។

–ឯងយ៉ាងម៉េចហ្នឹងខេមរិន្ទ?... អូ! ឈាម ហេតុអីបានក្លាយទៅជាអីចឹង? ដូរខោអាវទៅ! គ្នានាំឯងទៅពេទ្យ។

–អត់ប្រយោជន៍ទេ... គ្នាដឹងថាគ្នាមានបញ្ហាអ្វី ឯងមិនចាំបាច់បារម្ភអំពីគ្នាទេ ។ តោះ! យើងរៀនតទៅទៀត។

–ឯងឆ្កួតទេឬ? អោយគ្នារៀនយ៉ាងម៉េចបើឯងក្អករហូតដល់មានឈាមបែបនេះ? បើគ្នាគិតតែអំពីអនាគតរបស់គ្នា មិនគិតពីឯងគ្នាមិនព្រមទេ ព្រោះវាជាក្តីស្រមៃរបស់ពួកយើងទាំងពីរ មិនមែនរបស់គ្នាតែម្នាក់ឯណា ដូច្នេះបើចង់អោយវាសម្រេចទៅបានក៏ទាល់តែមានឯងនៅក្បែរដែរ ។

–បាន! គ្នាប្រាប់ឯងចុះ ។

ខេមរិន្ទរៀបរាប់អំពីស្ថានភាពនៃជម្ងឺអោយណារ៉ាបានដឹងទាំងអស់ ព្រមទាំងពេលវេលាដែលនឹងមកដល់ក្នុងពេលខាងមុខនេះទៀតផង។ ណារ៉ាស្ទុះអោបខេមរិន្ទ ហើយយកដៃទះខ្នងខេមរិន្ទតិចៗរួចនិយាយ :

–ពុទ្ធោសម្លាញ់! ឯងជាមិត្តតែម្នាក់របស់គ្នា បើគ្នាគ្មានឯងអោយគ្នារស់យ៉ាងម៉េចទៅ?

–ណារ៉ា! មុននឹងគ្នាឃ្លាតពីឯង...គ្នាសុំតែម្យ៉ាងប៉ុណ្ណោះ គឺចង់អោយឯងយល់ពីអត្ថន័យនៃពាក្យថាមិត្តអោយបានច្បាស់ គ្នាមិនចង់ឮឯងសួរគ្នានូវសំនួរឆ្កួតៗដូចលើកមុនទៀតទេ... ឯងចាំទេ? ថ្ងៃមួយមិត្តភក្តិយើងជាច្រើនបាននាំគ្នាទៅលេងវាំង ម្នាក់ៗសុទ្ធតែមានម៉ូតូជិះគ្រប់គ្នាហើយខ្វះក៏ដោយសារ ទៅតាមមិត្តភក្តិនៅសល់តែយើងពីរនាក់ដែលជិះកង់ដូចគ្នា ។ ពេលនោះឯងសួរគ្នាថា តើគ្នាជិះកង់ទៅ រឺក៏ជិះម៉ូតូជាមួយមិត្តភក្តិ? ឯងដឹងទេ?... ពេលគ្នាឮសំនួរនេះគ្នាឈឺចាប់ណាស់ព្រោះយើងជាមិត្តល្អនឹងគ្នាហេតុអីក៏ចាំបាច់សួរសំនួរបែបនេះ? តើឯងគិតថាគ្នាជាមនុស្សបែបណា ? ជាមនុស្សអត្តទត្ថបុគ្គលជាមនុស្សអាត្មានិយម ដូចដែលឯងគិតនោះឬ? តើឯងគិតថា គ្នានឹងទៅជិះម៉ូតូជាមួយមិត្តភក្តិ ហើយទុកអោយឯងជិះកង់តែម្នាក់ឯងឬ ? មិត្តភក្តិ!... ទោះទើបតែរាប់អានគ្នាបានមួយថ្ងៃក៏គេមិនដែលទុកមិត្តភក្តិចោលដូចនេះដែរ...។ ពាក្យថាមិត្ត វាមានអត្ថន័យខ្លាំងក្លានិងជ្រាលជ្រៅណាស់ ។ មិត្ត!... សំរាប់គ្នាមានតំលៃលើសជីវិតរបស់គ្នាទៅទៀត ។ មិត្តមិនមែនគ្រាន់តែ

ស្គាល់គ្នាហើយបោះបង់ចោលនោះទេ ហើយមិត្តក៏មិនមែនស្គាល់គ្នាដើម្បីតែគិតពីប្រយោជន៍ រៀងខ្លួននោះដែរ ...ថ្ងៃក្រោយ គ្នាមិនចង់ស្តាប់សំនួរបែបនេះទៀតទេ តើបានទេ?...

រាត្រីនោះបានកន្លងផុតទៅ... ឯពេលវេលាក៏មិននៅស្ងៀម ធ្លេចបើកាមួយខែបានកន្លងផុតទៀតហើយ ។ ជម្ងឺខេមរិន្ទបានបង្ខំអោយគេសំរាកនៅតែលើគ្រែ ឯណារ៉ាវិញមួយថ្ងៃ គិតតែពីការផារលែងខ្វល់ពីការសិក្សា ព្រោះចង់ស្វែងរកប្រាក់ទិញថ្នាំ និងអាហារដែលសំបូរដោយវីតាមីន សំរាប់ថែរក្សាសុខភាពរបស់ខេមរិន្ទ ។ ប៉ុន្តែគេមិនអោយខេមរិន្ទដឹងទេថាការសិក្សារបស់គេមានការថយចុះ ។ ណារ៉ាពេលនេះលែងខ្វល់អ្វីទាំងអស់ ហើយក៏ចេះស្គាល់ការតស៊ូជាបណ្តើរៗនៅពេលដែលជីវិតជួបបញ្ហា។នាយប់មួយ ពេលដែលណារ៉ាមកដល់ផ្ទះ ខេមរិន្ទបានហៅណារ៉ាអោយមកក្បែរដោយបំណងនិយាយពាក្យដ៏ច្រើនប្រាប់ទៅណារ៉ា :

–ឈប់ប្រឹងតទៅទៀតទៅសម្លាញ់! គ្នាដឹងថាឯងហត់ហើយ ។ គ្នាចង់អោយឯងគេងលក់ស្កប់ស្កល់ក្នុងយប់នេះ ។ ណារ៉ាទំលាក់ទឹកមុខដើរទៅជិតខេមរិន្ទដោយក្តីអស់សង្ឃឹម ហើយគេបានអង្គុយបែរខ្នងលើកដៃក្តោបមុខដោយមិនមាននិយាយអ្វីក្រៅពីការដកដង្ហើមធំនោះឡើយ ។ ខេមរិន្ទលើកដៃដាក់លើខ្នងណារ៉ាហាក់ដូចជាបញ្ជាក់នូវភាពជូរចត់នៅក្នុងខ្លួនហើយខំប្រឹងហារមាត់និយាយជាមួយណារ៉ា :

–ទោះបីថ្ងៃស្អែកឯងត្រូវគ្មានគ្នានៅក្បែរក៏ដោយ ក៏ឯងត្រូវចាំសន្យាថា នឹងសាងក្តីស្រមៃរបស់ពួក យើងអោយលេចចេញជារូបរាងឡើង ។ នៅពេលដែលឯងធ្វើបានសម្រេចនោះ ឯងនឹងមានភាពសប្បាយរីករាយព្រមជាមួយមុខមាត់ក្នុងសង្គមមួយនេះ ។ ឯងត្រូវធ្វើជាមនុស្សមានប្រយោជន៍នៅក្នុងសង្គមមិនមែនបញ្ញើសង្គមទេ គ្នាដឹងថាឯងមានសារជាតិជាមនុស្សស្លូតបូត ដូច្នេះសូមឯងកុំប្រែសារជាតិព្រោះតែរបស់កខ្វក់អោយសោះ។

–គ្នាយល់ហើយ! ប៉ុន្តែគ្នាត្រូវការឯងច្រើនជាងអ្វីទាំងអស់ ។ គ្នាមិនយល់ទេ ហេតុអីបានជាព្រហ្មលិខិតលេងសើចនឹងពួកយើងខ្លាំងម្ល៉េះ? តើវាមានបេះដូងទេ?... ទោះបីគ្រប់យ៉ាងគ្រាន់តែជាមិត្តភាពមួយ ប៉ុន្តែតំលៃនៃពាក្យថាមិត្តនេះគឺវាមានន័យធំធេងណាស់សំរាប់គ្នា ហើយគ្នាក៏រីករាយបើគ្នាអាចដូរជីវិតគ្នាយកជីវិតឯងមកវិញបាន។

–បំភ្លេចចោលចុះ ទោះបីតទៅគ្នាជាព្រលឹងដែលគ្មានសំបកក៏គ្នានៅរង់ចាំមើលការប្រព្រឹត្តរបស់ឯងជានិច្ច។

–សម្លាញ់!...

*ណារ៉ានិយាយបណ្តើរ ផាកស្ទុះអោបខេមរិន្ទបណ្តើរ ។ ពួកគេឱបអោបគ្នាទាំងពីរនាក់ ប៉ុន្តែពួកគេមិនគិតថា វាជាភាពទន់ជ្រាយទេ ហើយពួកគេបែរជាយល់ថា មនោសញ្ចេតនាដ៏ជ្រាលជ្រៅ នៃពួកគេទាំងពីរ គឺជាជម្រៅចិត្តដ៏សែនជ្រៅហើយគប់កំបាំងដោយអារម្មណ៍និងអនុស្សាវរីយ៍ដ៏ក្រាស់ក្រែល ។ នាព្រឹកឡើង ណារ៉ាក្រោករៀបចំថ្នាំ និងបបរសំរាប់ខេមរិន្ទតាំងពីម៉ោងប្រាំ ។ ចៃដន្យពេលកំពុងរៀបចំថ្នាំ និងទុកដាក់សៀវភៅដែលនៅរាត់រាយលើតុ ណារ៉ាបានធ្វើអោយជ្រុះសៀវភៅកំណត់ហេតុរបស់ខេមរិន្ទ សន្លឹកក្រដាសក៏ផ្ទាត់ទៅដល់ទំព័រមួយដែលមានដាក់ចំណងជើងថា "ទឹកមិត្តត្បិតដីងខុស" ដែលមានសេចក្តីដូចតទៅ :*

ថ្ងៃទី១០ខែធ្នូឆ្នាំ២០០៥

រឿងដែលខ្ញុំនឹងត្រូវសរសេរក្នុងពេលបន្តិចទៀតនេះ គឺជារឿងដែលខ្ញុំតែងតែពិបាកចិត្ត កើតទុក្ខខ្វល់ខ្វាយ និងសោកស្តាយជាទីបំផុត។ រឿងនេះ ខ្ញុំសរសេរដើម្បីដាស់ប្រាប់សង្គមមនុស្សទាំងអស់ កុំអោយមានទំលាប់ធ្វើដូចខ្ញុំតទៅទៀត ។ ថ្ងៃនេះជាទិវាបុណ្យសិទ្ធិមនុស្ស ខ្ញុំនៅផ្ទះមើលទូរទស្សន៍។ ចំណងជើងភាពយន្តមួយ បានលេចត្រដែតឡើង *"ចំណងមិត្តភាពអមតៈ"* ។ រឿងនេះបានធ្វើអោយខ្ញុំនឹកទៅដល់មិត្តម្នាក់ឈ្មោះ **សក្កា** គេតែងធ្វើល្អនឹងខ្ញុំ រាប់អានខ្ញុំ ចង់បានខ្ញុំធ្វើជាមិត្តល្អរបស់គេ ។ ចំណែកខ្ញុំចូលចិត្តបង្ករឿងឈ្លោះណាស់ ខ្ញុំចូលចិត្តសុំបែកគ្នា ព្រោះខ្ញុំគិតថាខ្ញុំ និងគេមិនអាចរាប់គ្នាជាមិត្តបានទេ...។ ខ្ញុំជាមនុស្សគិតច្រើន... ចូលចិត្តចាប់កំហុសគេ តែកំហុសខ្លួនឯងមើលមិនឃើញឡើយ ។ ខ្ញុំធ្លាប់សរសេរសំបុត្រទៅគេ ដើម្បីផ្សារភ្ជាប់ចំណងមិត្តភាពឡើងវិញ បន្ទាប់ពីចំណងមិត្តភាពនោះត្រូវបានបែកបាក់ដោយសារខ្ញុំ រួចមក ។ អត្ថន័យក្នុងសំបុត្របានបញ្ជាក់ថា បើមានបញ្ហាបែកបាក់នេះកើតឡើងម្តងទៀត ខ្ញុំនិងគេនឹងមិនអាចរាប់គ្នាជាមិត្តរៀងរហូត... ។ ការសន្យានេះបានធ្វើអោយខ្ញុំស្តាយក្រោយ... ពេលខ្ញុំឃើញអ្នកដទៃមានមិត្តភក្តិស្និទ្ធស្នាល ខ្ញុំតែងនឹកដល់គេ... ពេលខ្ញុំមានអារម្មណ៍ថាឯកោ ខ្ញុំក៏នឹកដល់គេ...។ ពេលដល់រដូវបុណ្យភ្ជុំម្តងៗ ខ្ញុំតែងនឹកគេខ្លាំងណាស់ រហូតអង្គុយសម្រក់ទឹកភ្នែកដោយសារតែគេ... នេះក៏ព្រោះតែខ្ញុំនឹកទៅដល់អនុស្សាវរីយ៍ចាស់ៗដែលធ្លាប់មានពីមុន...។ យើងធ្លាប់ជិះកង់ទៅលេងវត្តនាខែភ្ជុំបិណ្ឌជាមួយគ្នា យើងដើរ លេងជាមួយគ្នា យើងធ្វើបុណ្យរួមគ្នា ពិតជាមានសេចក្តីសុខណាស់ ។ ខ្ញុំចង់អោយពេលវេលានេះ មានសំរាប់ខ្ញុំម្តងទៀតហើយខ្ញុំនឹងធ្វើអ្វីៗតាំងអស់ដើម្បីគេ... តែនេះគ្រាន់តែជាការស្រមើស្រមៃមួយដ៏ឆោតល្ងង់ប៉ុណ្ណោះ ព្រោះពេលវេលាមិនអាចវិលត្រលប់ថយក្រោយបានទេ ហើយខ្ញុំក៏មិនអាចក្បត់សន្យារបស់ខ្លួនឯងបានដែរ ។ ជាងនេះទៅទៀត គេក៏លែងនៅជិតខ្ញុំដែរ គេបានឃ្លាតឆ្ងាយពីខ្ញុំហើយ...ឃ្លាតឆ្ងាយដោយខ្ញុំនិងគេនៅតែមិនទាន់យល់ចិត្តគ្នាច្បាស់ ឃ្លាតឆ្ងាយដោយខ្ញុំនិងគេមិនអាចធ្វើជាមិត្តល្អនឹងគ្នាបានដដែល...នេះហើយជាលទ្ធផលរបស់ខ្ញុំ ។

ដោយសារតែពាក្យសន្យា! ដោយសារតែពាក្យសម្បថ! ថ្ងៃក្រោយមកបើទោះជាខ្ញុំបានជួបគេ ក៏ខ្ញុំបានត្រឹមតែញញឹមទាំងឈឺចាប់ប៉ុណ្ណោះ ។ ខ្ញុំមិនអាចហាមាត់និយាយស្តីអ្វី អោយដូចដែលខ្ញុំបានគិតនៅក្នុងចិត្តនេះឡើយ ។ ពេលនេះខ្ញុំនៅសល់តែទឹកភ្នែកវិប្បដិសារីប៉ុណ្ណោះ គឺទឹកភ្នែកដែលស្តាយស្រណោះចំពោះសម្តីដែលគ្រលាស់ចេញមកដោយមិនបានគិតពិចារណា ជាពាក្យសម្តីដែលស្តីចេញទាំងកំហឹងឈឺចាប់ខ្វះការគិតអោយបានច្បាស់ ហើយសម្តីនេះកាលបើខ្ញុំបានខ្ជាក់ហើយ ខ្ញុំមិនអាចលេបវិញបានទេ...

ដោយសារតែវិប្បដិសារីនេះហើយ ទើបខ្ញុំបានសន្យាចំពោះខ្លួនឯងថា *ថ្ងៃណាមួយពេលខ្ញុំមានមិត្តភក្តិដែលចិត្តល្អចេះយល់ ចិត្តគ្នា មានអធ្យាស្រ័យ និងពលិកម្មខ្ពស់សមជាកល្យាណមិត្តដូចនេះទៀត ខ្ញុំនឹងធ្វើអ្វីៗគ្រប់បែបយ៉ាងដើម្បីគេទោះបីជីវិតខ្ញុំក៏ខ្ញុំលះបង់ដែរ ។ ខ្ញុំមិនចង់អោយពេលវេលាកន្លងផុតទៅដោយបន្សល់នូវតែវិប្បដិសារីដូចនេះទៀតឡើយ។*

*ណារ៉ាមើលបណ្ដើរស្រក់ទឹកភ្នែកបណ្ដើរ គេគិតថាខេមរិន្ទជាមនុស្សដែលពោរពេញដោយមនោសញ្ចេតនា ជ្រាលជ្រៅណាស់។ ណារ៉ានៅចាំបានថា ពេលខេមរិន្ទមានទុក្ខ ខេមរិន្ទចូលចិត្តអង្គុយ ត្រមង់ត្រមោចម្នាក់ឯងនៅកន្លែងស្ងាត់ៗដែលគ្មានសំលេងរំខាន... ដូចជានៅក្នុងបណ្ណាល័យរឺតាមវាលស្មៅជាដើម គេអង្គុយណែតអារម្មណ៍ទៅតាមពេលវេលាហាក់គ្មានស្ដាយស្រណោះសោះ បើទោះជាគេធ្លាប់គិតថាពេលវេលាមានតំលៃយ៉ាងណាក៏ដោយ... ជាមួយនឹងភាពស្រងេះស្រងោចនេះណារ៉ាក៏ធ្លាប់បានឃើញតំណក់ទឹកភ្នែកហូរមករឹមៗ ចេញពីប្រឡង់ភ្នែករបស់គេដែរ តែពេលនោះណារ៉ាហាក់ដូចជាមិនចាប់អារម្មណ៍នឹងទុក្ខព្រួយ របស់មិត្តភក្តិសោះ...។ ណារ៉ាខំសំរួលដង្ហើមឡើងវិញ ហើយយកដៃជូតទឹកភ្នែកចេញអស់ទើបបន្តផ្ទាត់សន្លឹកសៀវភៅទៅមុខទៀតក៏ឃើញអត្ថបទគ្មានចំណងជើងមួយដែលមានសេចក្ដីថា :*

ថ្ងៃទី១១ខែឧសភាឆ្នាំ២០០៦

ខ្ញុំមិនដឹងសោះឡើយ ថា ហេតុអីបានជាចិត្តរបស់ខ្ញុំខុសគេយ៉ាងនេះ?ខ្ញុំតែងមានចិត្តនឹកគិតពីមិត្តភក្តិជានិច្ចខ្ញុំគិតណាស់គិតរហូត ដេកក៏មិនលក់ ញុំាបាយក៏មិនឆ្ងាញ់... នេះមកពីអ្វី? មកពីខ្ញុំចាត់ទុកមិត្តភក្តិជាជីវិតរបស់ខ្ញុំដែរ? មិត្តល្អទោះបែកមួយថ្ងៃក៏ដូចបែកមួយឆ្នាំដែរ... ។ ខ្ញុំនឹក! នឹកគ្រប់វេលា មុខខ្ញុំមិនដែលរីកក៏ព្រោះតែមិត្តភក្តិ។ ខ្ញុំមើលទៅ មិត្តរបស់ខ្ញុំម្នាក់ណាក៏ដូចជាម្នាក់ណា មើលទៅគេដូចជាមិនដែលគិតរឺនឹកខ្ញុំបន្តិចសោះ... គេមិនដែលយល់ទេថាចិត្តខ្ញុំបែបណា គេមិនយល់ពីអារម្មណ៍ខ្ញុំបន្តិចសោះ ... ដូចជាពេលនេះអីចឹង មិត្តល្អរបស់ខ្ញុំណារ៉ាខានមកដេកផ្ទះមួយអាទិត្យហើយ ។ គេមិនដឹងទេថាខ្ញុំបារម្ភពីគេយ៉ាងណា ហើយថ្ងៃនេះគេនឹងកាន់តែឃ្លាតឆ្ងាយពីខ្ញុំទៀតហើយ ព្រោះគេត្រូវទៅលេងស្រុកកំណើតមួយរយៈ ។ ថ្ងៃចុងក្រោយនៃការបែកគ្នា មិត្តភក្តិគួរណាស់តែផ្ដល់ពេលវេលាសំរាប់គ្នាអោយបានច្រើនមុននឹងបែកគ្នា...។តែនេះអត់ទេ គេបែរជាព្រងើយកន្តើយមិនយល់ពីអារម្មណ៍ខ្ញុំបន្តិចសោះ។ នេះប្រហែលជាគេគិតថា ពេលវេលាប្រាំមួយថ្ងៃនៃការបែកគ្នាវាគ្មានអ្វីសំខាន់ហើយ មើលទៅ។ សូម្បីតែព្រឹកមិញនេះ គេមករៀនអង់គ្លេសខកបន្តិចក៏ខ្ញុំអន្ទះអន្ទែងជ្រួលច្របល់ដែរ... ខ្ញុំខ្លាចគេមានរឿងអ្វី... ឈឺរឺក៏គេទៅស្រុកដោយមិនបានលាខ្ញុំ? បើដូច្នោះមែនវាជារឿងមួយដែលគួរអោយឯកោស្រងេះស្រងោចណាស់...។ តែនេះគេមិនបានយល់ចិត្តខ្ញុំអី ពេលខ្ញុំសួរពីមូលហេតុ គេបែរជាឆ្លើយយ៉ាងសោះកក្រោះថា *ព្រោះតែមកឃីតហ្នឹងអ្ហា! បានមកខក... ឆ្ងល់ច្រើនមែន!...* ថ្ងៃនេះដដែល វេលាម៉ោងបួនរសៀល ក្រោយបញ្ចប់មេរៀនអរិយធម៌ ខ្ញុំបានមកអង្គុយនៅក្រោមបណ្ណាល័យ ដោយបានប្រាប់ណារ៉ាទៀតផង ។ ខ្ញុំគិតថា បើណារ៉ាយល់ពីអារម្មណ៍មិត្តភក្តិក្នុងថ្ងៃចុងក្រោយនៃការបែកគ្នា គេពិតជាមក រកខ្ញុំដើម្បីនិយាយលេងមិនខាន... ព្រោះពាក្យថាលា និង ពាក្យជូនពរផ្ដល់កម្លាំងចិត្ត ខ្ញុំមិនទាន់បានទទួលនៅឡើយទេ ។ ខ្ញុំសង្ឃឹមថាគេនឹងមកហើយខ្ញុំនឹងរង់ចាំគេរហូតដល់ម៉ោងប្រាំ។ តែបើមិនឃើញគេមក ... នោះរយៈពេលនៃការឈប់នេះ នឹងមិនធ្វើអោយខ្ញុំមានសេចក្ដីសុខឡើយ។...................... នាឡិកាចេះតែវាត់ទ្រនិចដើរឥតឈប់.... មិនយូរប៉ុន្មានម៉ោង ប្រាំក៏ខិតជិតមកដល់........... ពេលនេះម៉ោងប្រាំបានចូលមកដល់ហើយ! ឯណាទៅមិត្តខ្ញុំ? គេទៅណាបាត់ហើយ ហេតុអីគេមិនមករកខ្ញុំ? តើ គេមិនបានគិតទេរឺថាខ្ញុំមានអារម្មណ៍បែបណានោះ? តើមិត្តល្អពេលទៅលេងស្រុក អត់មានប្រាប់មិត្តភក្តិមួយម៉ាត់ដូច្នេះ ឬ? ហេតុអីមិត្តរបស់ខ្ញុំទាំងអស់សុទ្ធតែមិនយល់ចិត្តខ្ញុំសោះអីចឹង? ឱបណ្ណាល័យអើយ! សូមអ្នកជួយប្រាប់មិត្តសម្លាញ់ខ្ញុំ ផង ថាទីនេះហើយដែលខ្ញុំតែងទន្ទឹងចាំគេគ្មានពេលភ្លេច... *"មិត្តយល់ចិត្តពិតមិត្តល្អ"*

ក្រោយពីណារ៉ាបានអានកំណត់ហេតុរបស់ខេមរិន្ទរួចមក ណារ៉ាមានសេចក្តីសោកស្តាយខ្លាំងណាស់ចំពោះ កំហុសឆ្គងរបស់ខ្លួនចំពោះមិត្ត ។ គេទទួលស្គាល់ថា គេមានកំហុសមែននៅពេលនោះ ហើយគេក៏ពុំទាន់បានយល់ពីចិត្តរបស់ខេមរិន្ទ និងតំលៃនៃពាក្យថាមិត្តបានច្បាស់ដូចពេលនេះដែរ ។ ណារ៉ាបិទសៀវភៅទុក ហើយឈ្ងោកមុខយំខ្សឹកខ្សួល :

-ខេមរិន្ទ! ហេតុអីបានជាឯងទ្រាំឈឺចាប់តែម្នាក់ឯងដូច្នេះ? បើគ្នាមានកំហុស ហេតុអីឯងមិនប្រាប់គ្នាត្រង់ៗមកម៉េចចាំបាច់សរសេរលាក់ទុកតែម្នាក់ឯងដូច្នេះ ? អោយគ្នាសូមទោស... គ្នាខុសចំពោះឯងខ្លាំងណាស់សម្លាញ់!...

និយាយដូច្នេះរួច ណារ៉ាក៏ដើរទៅរកខេមរិន្ទ រួចដាស់តិចៗដោយក្តីបារម្ភ ក៏ប៉ុន្តែសំលេងស្រែកហៅមិនអាចធ្វើអោយខេមរិន្ទទទួលបានទៀតឡើយ ព្រោះខេមរិន្ទនៅពេលនេះមានតែសម្បកខ្លួនប៉ុណ្ណោះ។

-ខេមរិន្ទក្រោកឡើង! ក្រោកឡើង! ឯងកុំធ្វើអោយគ្នាភ័យណា..។ ខេមរិន្ទ! ឯងមិនត្រូវទុកគ្នាចោលទេ ក្រោកឡើង ។ អត់ទេ!... ឯងមិនត្រូវស្លាប់ទេ...ឯងចង់បានអី? ឯងប្រាប់គ្នាមកគ្នាបំពេញអោយ តែឯងមិនត្រូវទៅចោលគ្នាទេណាសម្លាញ់...។

ណារ៉ាអង្រួនសាកសពខេមរិន្ទជាមួយនឹងសម្លេងស្រែកហៅទាំងគ្មានន័យ ។ ណារ៉ាយំផង ឱបសពមិត្តផងហើយជេរបន្ទោសខ្លួនឯងផង។

-គ្នានេះអាក្រក់ណាស់! គ្នាមិនដែលបានបំពេញតួនាទីជាមិត្តដ៏ល្អទេ... គ្នាសូមទោស! ត្រលប់មកវិញមក គ្នាភ័យណាស់ ឯងត្រលប់មក! គ្នាត្រូវការឯង គ្នានឹកឯងណាស់សម្លាញ់...។

ស្លឹកឈើជ្រុះហើយ មិនអាចត្រលប់ទៅដុះជាប់ដើមវិញបានទេ... រីឯកូនបក្សីក៏ហោះចោលសម្បុកអ្វីៗមិនអាចស្ថិតស្ថេរជានិរន្តរ៍បានឡើយ ។ គ្រប់យ៉ាងត្រូវតែបណ្តោយទៅតាមព្រហ្មលិខិត ទោះបីពេលខ្លះវាត្រូវការទាមទារយកជីវិតមនុស្សជាទីស្រលាញ់របស់យើងក៏ដោយ។

ចាប់តាំងពីថ្ងៃនោះមក ណារ៉ាហាក់ដូចជាមនុស្សឯកោម្នាក់ដែលគ្មានគោលដៅ ។ គេគិតតែពីអង្គុយផ្អែកជញ្ជាំងអោបធាតុរបស់ខេមរិន្ទ ដែលមើលទៅគេហាក់ដូចជា គ្មានវិញ្ញាណនៅក្នុងខ្លួនទាល់តែសោះ ។ ទឹកដែលរលាយចេញពីកែវភ្នែករបស់ណារ៉ាគឺបញ្ជាក់មកជាមួយនូវភាពក្រៀមក្រំនិងការឈឺចាប់ហួសបរិយាយ ហើយពេលនោះគេបានគិតនៅក្នុងចិត្តតែម្នាក់ឯង :

-ចាប់តាំងពីពេលដែលគ្នាគ្មានឯង គ្នាពិតជាវេទនាណាស់... គ្នាតែងនឹកឃើញរាល់អនុស្សាវរីយ៍ ដែលកន្លងមក គ្នាចង់បានវាម្តងទៀត ។ គ្នាមិនចង់យំ តែគ្នាធ្វើមិនបានព្រោះមិត្តភាពយើងវាកប់ជ្រៅពេក គ្នាមិនដឹងថាត្រូវបំភ្លេចឯងដោយវិធីណាទេ ។ នៅពេលនេះអ្វីដែលគ្នាចង់ដឹងខ្លាំងបំផុតនេះគឺសុខទុក្ខរបស់ឯង តើឯងនៅទីណា? ឯងកំពុងតែធ្វើអ្វី? ចុះគ្នានឹកឯងនោះ ឯងមានដឹងទេ? គ្នាសូមសន្យាថាត្រូវតែសាងក្តីស្រមៃរបស់ពួកយើងអោយបានសម្រេច តែឯងត្រូវសន្យាថាឯង ត្រូវត្រលប់មករកគ្នាវិញ ទោះបីត្រឹមក្តីស្រមៃក៏ដោយណាសម្លាញ់។

ក្រោយពីបានសន្យានឹងខេមរិន្ទរួចមក ណារ៉ាចាប់ផ្តើមខិតខំម្តងទៀតដើម្បីសម្រេចអ្វីដែលពួកគេចង់បាន ហើយនៅរាល់ពេលដែលណារ៉ាសម្រេចបានមួយកំរិត ណារ៉ាតែងឈរមុខរូបថតវិញ្ញាណក្ខ័ន្ធខេមរិន្ទដើម្បីប្រាប់អំពីជោគជ័យរបស់គេ។ នៅទីបំផុត ណារ៉ាក៏ធ្វើបានសម្រេចមែន។ ណារ៉ាជាមនុស្សល្អខ្លាំងណាស់ ញាតិមិត្តណាក៏ស្រលាញ់និងរាប់អានគេព្រោះគេតែងធ្វើល្អចំពោះមនុស្សគ្រប់គ្នា ។ នាល្ងាចមួយ ក្រោយពិធីជប់លៀងសម្ពោធផ្ទះថ្មីរបស់ណារ៉ាចប់ ណារ៉ាបានដើរចូលទៅក្នុងបន្ទប់មួយ ដែលរៀបចំយ៉ាងស្អាតសម្រាប់ខេមរិន្ទ។ ណារ៉ាបានឈរសម្លឹងរូបថតខេមរិន្ទ ហើយនិយាយគ្នាលេង:

-គ្នាធ្វើបានសម្រេចហើយ គ្នាអរគុណដែលរាល់លើកគ្នាសម្លឹងមើលទៅឯង គ្នាឃើញឯងញញឹមមកកាន់គ្នាជានិច្ច ប៉ុន្តែគ្នាបែរជាយំទៅកាន់ឯងវិញ ។ ដូច្នេះចាប់ពីថ្ងៃនេះតទៅ គ្នាគួរតែមានស្នាមញញឹមសម្រាប់ឯងដែរ ។ ឯងញ៉ាំត្របែកទេ គ្នាចិតអោយ ព្រោះរាល់លើកឯងជាអ្នកចិតអោយគ្នា ។ ទោះវាជារបស់ដែលឯងចូលចិត្ត ប៉ុន្តែឯងមិនដែលភ្លេចគ្នាទេ មានពេលខ្លះគ្នាញ៉ាំច្រើនជាងឯងទៀត ។ បើគិតទៅពេលនោះគ្នាចង់តែសើចទេ ហើយគ្នាចង់ត្រលប់ទៅកាលពីក្មេងវិញព្រោះពេលនោះគ្នាមានអារម្មណ៍ថាសប្បាយខ្លាំងណាស់ ។ ពួកយើងធ្លាប់ងូតទឹកប្រឡាយជាមួយគ្នា ពួកយើងធ្លាប់លួចបេះស្វាយគេ ពួកយើងដាំត្របែកដើម្បីញ៉ាំទាំងអស់គ្នា ។ មានពេលមួយ ឯងធ្វើអោយគ្នាខឹងណាស់ ព្រោះឯងយកសៀវភៅរបស់គ្នាហែកចោល តែគ្នាក៏មានអារម្មណ៍ល្អវិញ នៅពេលដែលឯងជួយសរសេរអក្សរទាំងអស់ឡើងវិញសងអោយគ្នា ។ ថ្ងៃស្អែកគ្នារៀបការហើយ តើឯងមកចូលរួមដែរទេ? តែកុំបារម្ភ ទោះជាយ៉ាងណាក៏ឯងត្រូវតែចូលរួមដែរព្រោះចាប់ពីថ្ងៃនេះតទៅ ពួកយើងនឹងរស់នៅក្នុងផ្ទះនេះជុំជាមួយគ្នារហូត ហើយបន្តិចទៀតឯងនឹងឃើញក្មេងរាដែលត្រូវជាក្មួយរបស់ឯង ពួកគេនឹងរត់លេងនៅទីនេះទៀតផង ។ក្រែងឯងចូលចិត្តក្មេងនោះអី? ម៉េចក៏មិនឆ្លើយ

នឹងគ្នាមក? ត្រូវហើយព្រោះឯងពេលនេះលែងចង់និយាយហើយ  ឯងគិតតែពីសើចប៉ុណ្ណោះ ។ សម្លាញ់ជឿទេ? បើសិនជាពេលនេះ  គ្នាអាចដូរគ្រប់យ៉ាងទោះបីជីវិតអាពាហ៍ពិពាហ៍  រឺក៏ជីវិតរបស់គ្នាផ្ទាល់ក៏គ្នាព្រមដូរដែរ អោយតែឯងមានជីវិតរស់ឡើងវិញ  ហើយយើងនឹងត្រលប់ទៅស្រុកកំណើតវិញជាមួយគ្នា  យើងនឹងរស់នៅតាមជីវភាពធម្មតាជាមួយនឹងការលេងសើចដូចពេលមុន។ គ្នាអាចចាំបាន  នៅរាល់យប់ដែលគ្នារងាគេងអោបដៃគឺឯងជាអ្នកយកភួយមកដណ្តប់អោយគ្នា ។ ពេលគ្នាមានរបួស  គ្នាមើលទៅឯងដូចជាឈឺជាងគ្នាទៅទៀត ។ ពេលគ្នាសើចគឺជាសេចក្តីសុខរបស់ឯង តើមែនទេ? មែនហើយ  ឯងធ្លាប់ប្រាប់គ្នាថា ឯងសប្បាយចិត្ត ណាស់នៅពេលឃើញគ្នាសើចយ៉ាងនេះ ។  ចុះពេលដែលគ្នាយំ  តើឯងលំបាកចិត្តខ្លាំងយ៉ាងណា?  អោយគ្នា សូមទោសដែលកន្លងមក គ្នាធ្វើអោយឯងមិនសប្បាយចិត្ត ប៉ុន្តែតទៅគ្នាលែងអោយឯងឃើញ ទឹកភ្នែក របស់គ្នា ទៀតហើយ ។  គ្នាសូមអរគុណ  ដែលឯងមានទឹកចិត្តសម្រាប់គ្នាជារហូតមក  ហើយគ្នាប្រាកដ  ជាចងចាំនូវគ្រប់ទង្វើល្អរបស់ឯង ។ ឯងជាវត្ថុដែលមានតំលៃបំផុតក្នុងជីវិតរបស់គ្នា  ឯងជាមនុស្សទីមួយដែល  បង្ហាញអោយគ្នាស្គាល់សេចក្តីសុខពិតតាមរយៈស្នាមញញឹម  និងតម្លៃពិតរបស់មិត្តល្អ  ។  ប៉ុន្តែគួរអោយ  ស្តាយណាស់ដែលក្នុងពេលនេះសូម្បីតែសាច់របស់ឯងត្រជាក់រឺក្តៅក៏គ្នាមិនអាចស្ទាបដឹងផង ។ យប់ណាស់ ហើយ  រាត្រីសួស្តីណាសម្លាញ់!...

ណារ៉ាទាញទ្វារបន្ទប់បិទរួចដើរទៅកាន់បន្ទប់របស់គេទាំងទឹកមុខស្រងូតស្រងាត់  ហើយណារ៉ាក៏យំម្តងទៀតដោយស្ងាត់ៗ ព្រោះគេមិនចង់យំនៅចំពោះមុខរូបថតខេមរិន្ទទេ។

ពេលវេលាមិនអាចត្រលប់ក្រោយបានទេ ហេតុដូចនេះចូរមិត្តទាំងអស់គ្នាធ្វើល្អចំពោះគ្នាទៅវិញ ទៅមកមុនពេលអ្វីៗទាំងអស់សល់ត្រឹមពាក្យថា "**យឺតពេល** "។

# ចប់